**រាជបណ្ឌិត្យសភាកម្ពុជា**

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## - ភាគទី៥ - វគ្គទី៣

**អត្ថបទចងក្រងដោយ៖ លោកស្រី ស៊ីន ច័ន្ទអមរា**
**មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា**

នៅក្នុងវគ្គទី៣ ដែលជាវគ្គបញ្ចប់នៃភាគទី៥នេះ យើងសូមបង្ហាញអំពីលិខិតរបស់លោកឡឺរេស៊ីដង់ សុប៉េរីយ៉ើរ[1] និងលោកឡឺរេស៊ីដង់ក្រុមមឿង[2] ចំនួន២ច្បាប់ផ្ញើទៅកាន់លោកសេនាប្រមុខ សុព រួមទាំងលិខិតឆ្លើយតបរបស់លោកសេនាប្រមុខ សុព ដែលមានខ្លឹមសារដើម និងកែសម្រួលដូចខាងក្រោម៖

**គ-ទូរលេខឆ្លើយឆ្លងរវាងលោកឡឺរេស៊ីដង់ សុប៉េរីយ៉ើរ, លោកឡឺរេស៊ីដង់ក្រុមមឿង និង លោកសេនាប្រមុខសុព**

- **លិខិតទី១របស់លោក រេស៊ីដង់ សុប៉េរីយ៉ើរ បូឌូវាំង (Baudoin)**

*ភ្នំពេញនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩២៥*

*ផ្ញើជូនលោកមេទ័ពម៉ារេសាល់សុព នៅទីក្រុងប៉ារីសតាមខ្សែលួស(ទូរលេខ)៖*

*ក្នុងឱកាសធ្វើបុណ្យឆ្លងវិមាន រំឭកគុណដល់អ្នកដែលទទួលអនិច្ចកម្មក្នុងចម្បាំងធំ គឺវិមានដែលលោកបានយល់ព្រម តាមសំណាករបស់ជាងចម្លាក់ ឌូក្វាំង*

[1] រេស៊ីដង់សុប៉េរីយ៉ើរ គឺរេស៊ីដង់ជាន់ខ្ពស់ដែលគ្រប់គ្រងប្រទេសកម្ពុជាទាំងមូលនាសម័យអាណាព្យាបាលបារាំង។

[2] រេស៊ីដង់ក្រុមមឿង គឺចៅហ្វាយក្រុងភ្នំពេញដែលជាមន្ត្រីបារាំង។

(Ducoing) *កាលលោកបានអញ្ជើញទៅក្រុងកម្ពុជានោះ ថ្ងៃនេះក្រុងភ្នំពេញបានយក«ផ្កាករំឭក»១ផ្កាំង ទៅបោះក្នុងបន្ទប់កិត្តិយស នៃទីរាជការក្រុមមឿងរំឭកដល់អ្នកមានជ័យជម្នះក្នុងចម្បាំងឡាម៉ានន៍*(La Marne) *ដែលបានអញ្ជើញមកក្នុងចំណោមយើង កាលខែធ្នូ ឆ្នាំ១៩២១។ ក្នុងឱកាសនេះខ្ញុំមានសេចក្ដីអំណរនឹងជូនមកលោកនូវសេចក្ដីដែលអាណាប្រជានុរាស្ត្រជាតិអឺរ៉ុប និងអ្នកស្រុកអាយ*[3] *ស្គាល់គុណជាអចិន្ត្រៃយ៍ ដល់មេទ័ពមានជ័យជម្នះនៃរាជការសាធារណរដ្ឋ។*

*រេស៊ីដង់ សុប៉េរីយ៉ើរ*

*បូឌូវាំង*

- **លិខិតទី២របស់លោករេស៊ីដង់ ក្រុមមឿង ប៉ា ទ្រី**

*ភ្នំពេញនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩២៥*
*ផ្ញើជូនមេទ័ពម៉ារេសាល់សុព នៅទីក្រុងប៉ារីសតាមខ្សែលួសៈ*

*ដោយមានគំនិតមេត្រីជាស្មោះត្រង់ នោះក្រុងភ្នំពេញក៏ធ្វើបុណ្យរំឭក ដែលលោកបានអញ្ជើញមកក្រុងកម្ពុជា រួបរួមជាមួយបុណ្យឆ្លងវិមានរំឭកគុណដល់អ្នកដែលទទួលអនិច្ចកម្មក្នុងចម្បាំងធំ។ សេចក្ដីនេះតាមលំនាំយ៉ាងខ្ពស់ពីលោក ឡឺរេស៊ីដង់ សុប៉េរីយ៉ើរបូឌូវាំងនោះ ក្រុងភ្នំពេញបានធ្វើ«ផ្កាករំឭក»បោះក្នុងថ្ងៃនេះ នៅទីរាជការក្រុមមឿងដែលជាន់នោះលោកបានទៅឈប់សំណាក់។ «ផ្កាករំឭក»១ផ្កាំងនេះគឺសម្រាប់រំឭកកេរ្តិ៍ដែលលោកបានស្នាក់អាស្រ័យនៅទីនោះ។ ក្នុងខណៈនេះ ខ្ញុំសូមជូនមកលោកតាងនាមអាណាប្រជានុរាស្ត្រ ដែលសេចក្ដីជំនុំក្នុងឆ្នាំ១៩១៨ នាំជួយនគរឱ្យរួចពីទុក្ខ។*
*រេស៊ីដង់ ក្រុមមឿង*
*ប៉ា ទ្រី*

[3] អ្នកស្រុកអាយ គឺប្រជាជននៅក្រោមអាណាព្យាបាលបារាំង ដូចជាប្រជាជនខ្មែរជាដើម។

- **លិខិតទី៣របស់លោកសេនាប្រមុខ សុព ឆ្លើយតបតាមខ្សែលួសមកលោករេស៊ីដង់ជាន់ខ្ពស់**

*ក្រុងប៉ារីសៈ នៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩២៥។*

*ជម្រាបមកអ្នកឡឺរេស៊ីដង់ សុប៉េរីយ៉ើរបានជ្រាប។*

*ខ្ញុំមានសេចក្តីរំជួលជាខ្លាំងអំពីសេចក្តីខ្សែលួស ដែលអ្នកបានវាយទៅខ្ញុំ ក្នុងឱកាសធ្វើបុណ្យឆ្លងវិមាននៅក្រុងភ្នំពេញ សម្រាប់រំឭកគុណដល់អ្នកដែលទទួលអនិច្ចកម្មក្នុងគ្រាចម្បាំងធំ។ ខ្ញុំនៅចាំនៅឡើយ សេចក្តីដែលបានចាត់ចែងទទួលខ្ញុំនៅក្នុងក្រុងនេះ ដើមឡើយគឺសេចក្តីដែលអ្នកបានរៀបចំទទួលខ្ញុំជាធំពន្ទឹក ដោយមេត្រីរាប់អាន។ ដោយមានឱកាសនេះស្រាប់ហើយនោះ ខ្ញុំមានសេចក្តីអំណរសាទរនឹងជូនមកអ្នក នូវសេចក្តីដែលខ្ញុំសូមឧទ្ទិសថាន[4]ឱ្យពរសូមឱ្យក្រុងកម្ពុជាធិបតី បានសេចក្តីថ្កើងរុងរឿងគ្រប់ប្រការ។*

*សូមអ្នកឡឺរេស៊ីដង់ សុប៉េរីយ៉ើរ ទទួលសេចក្តីរាប់អាន និងសេចក្តីមេត្រីស្និទ្ធស្នាលពិតប្រាកដពីខ្ញុំ។*

***សុព***

- **លិខិតទី៤របស់លោកសេនាប្រមុខ សុព ឆ្លើយតបតាមខ្សែលួសមកលោកចៅហ្វាយក្រុងភ្នំពេញ**

*ក្រុងប៉ារីសៈ នៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩២៥។*

*ជម្រាបមកអ្នកឡឺរេស៊ីដង់ ក្រុមមឿងជ្រាប។*

*ខ្ញុំនៅចាំដោយរំជួល សេចក្តីដែលខ្ញុំបានធ្វើដំណើរមកក្រុងកម្ពុជា ហើយនិងសេចក្តីដែលអស់លោកអស់អ្នកបានរៀបចំទទួលខ្ញុំនោះ ខ្ញុំពុំមានភ្លេចសោះឡើយ។ ខ្ញុំមានសេចក្តីរំជួលជាខ្លាំង អំពីការដែលអ្នកបានគិតចាត់ចែងបោះ«ផ្លាករំឭក»១ផ្ទាំង នៅទីរាជការក្រុមមឿងក្រុងភ្នំពេញ សម្រាប់រំឭកថ្ងៃ ខែ ឆ្នាំ ដែលខ្ញុំបានមកសំណាក់នៅទីនេះ។ ខ្ញុំមានសេចក្តីអំណរសាទរនឹងជូនមកអ្នកនូវសេចក្តីដែលខ្ញុំសូមឧទ្ទិសថានឱ្យ*

---

[4] «ឧទ្ទិសថាន» គឺ«អធិដ្ឋាន» ដែលមានន័យថា ការតាំងចិត្តនឹកតម្រង់ចំពោះ, វនានុក្រមខ្មែរពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៧, ទំព័១៦០៥។

*ពរដើម្បីឱ្យក្រុងភ្នំពេញដ៏ល្អសំខាន់ព្រមទាំងខ្លួនអ្នក បានសេចក្តីចំរើនរុងរឿងតរៀង ទៅ។*

*សុព*

បន្ទាប់ពីលិខិតទាំង៤នេះ ឯកសារស្តីពីបុន្យឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិបិ្ត, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨) បានរៀបរាប់ដូចតទៅ[5]៖

កាលធ្វើបុណ្យបោះ«ផ្លាករំឭក»រួចនោះ ប្រហែលជាម៉ោង១១ ក៏ពួកភ្ញៀវ ដែលរាជការក្រុមមឿង បានអញ្ជើញទៅក្នុងឱកាសនេះ ព្រមទាំងអ្នកស្រុកអាយជាច្រើន ដែលបានទៅមើលជាកម្សាន្តនៅទីរាជការក្រុមមឿងក៏ថយត្រឡប់ទៅទិសទីទៃៗរៀងខ្លួន។ ក្នុងពេលព្រឹកថ្ងៃសៅរ៍នឹងមានធ្វើបុណ្យអ្វីក្រៅពីនេះទៅទៀតក៏គ្មាន។ ឯបណ្តារាស្រ្តគ្រប់ភាសា ដែលទៅជួយហែនៅថ្ងៃស្អែកព្រឹកនោះ ក៏រវល់រៀបចំដោយសព្វខ្លួន។ ក៏ប៉ុន្តែក្នុងកំឡុងថ្ងៃសៅរ៍នោះឯង មានអាណាប្រជានុរាស្រ្តជាតិយួន ខ្មែរ ចិន និង ចាមជ្វា ដើរខ្នាន់ខ្នាប់ទៅកាន់ទីវិមានរូបដែលសាងទុកនោះ។ ឯវិមាននោះខាងលើនៅគ្របសំពត់នៅឡើយនឹងមើលរូបពុំឃើញទេ មើលឃើញតែជើងកុះធ្វើពីថ្មកែវ តម្កល់លើស្មាដំរីបួនធ្វើពីសំរិទ្ធិ។ ក្នុងក្រុងភ្នំពេញ នៅទីដែលសាងវិមាននេះសព្វមួយដងធ្លាប់តែស្ងាត់ច្រៀប ម្តងនេះចេះតែមានមនុស្សដើរជ្រួលច្របល់[6]ទៅកាន់ទីនោះ រហូតដល់ពេលយប់ ដែលមានហែភ្លើងជាបុណ្យបង្ហើយក្នុងថ្ងៃនោះ ទើបបណ្តារាស្រ្តត្រឡប់ទៅមើលហែភ្លើងនៅឯកណ្តាលទីក្រុងនោះវិញ។

ឯបុណ្យហែភ្លើងនេះ ក៏គួរឱ្យបណ្តារាស្រ្តទៅមើលមិនឥតប្រយោជន៍នោះទេ។

រីបុណ្យហែភ្លើងនោះក៏ឃើញល្អចំណាប់ គួរឱ្យចូលចិត្តមើលពិតមែន ព្រោះក្រុមជំនួញក្នុងស្រុកព្រះបរមរាជវាំង និង ពួកចិនក៏បានជួយជ្រោមជ្រែងនាំឱ្យក្បួនហែបានល្អមាំមួនឡើង។ ឯត្រែរបស់ក្រុមទាហានបារាំងជើងគោក ក្រុមពិជ័យសង្គ្រាម និងភ្លេងបារាំង២វង់ គឺរបស់ក្រុមទាហានអុងស៊ីយាមកូឡូនីញ៉ាល់[7] ១វង់ និងព្រះរាជទ្រព្យព្រះករុណា ១វង់ ដែលមានភ្លេងទាហានក្រុមរក្សាស្រុកកំពង់ស្ពឺជួយអមផង

---

[5] បុន្យឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិបិ្ត, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥, ទំព័រ៧១-៧២។

[6] «ជ្រួលច្របល់» គឺ«ជ្រួលជ្រើម» ដែលមានន័យថា ជាពួកជាក្រុមពូនចុះពូនឡើង, វចនានុក្រមខ្មែរពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៧, ទំព័រ២៧៩។

[7] ក្រុមទាហាន«អុងស៊ីយាមកូឡូនីញ៉ាល់» (Onzième Coloniale) គឺទាហានអាណានិគម អង្គភាពទី១១។

ក៏បានផ្ដុំលេងយោងមុខ[8]អស់លោកពួកនាក់កាន់គោមមានរូបប្លែកៗ ហើយមានពណ៌គ្រប់យ៉ាង ដែលដើរតាមក្បួនហែជាជួរជាបន្ទាត់។

ឯក្បួនហែភ្លើងនេះ ចាប់ហែនៅម៉ោង៨យប់ ពីទីរេស៊ីដង្គក្រុមមឿង(សាលាក្រុងភ្នំពេញ) ហែទៅដល់ខាងព្រះបរមរាជវាំង នៅម៉ោង៩ កន្លះ ក៏ឈប់ហែបែកគ្នាចេញ។

ការហែភ្លើងនេះ នាំឱ្យមានសេចក្ដីកម្សាន្តរីករាយក្នុងផ្ទៃក្រុងទាំងមូល។

(សូមរង់ចាំអាននៅភាគបន្ត...)

[8] ផ្ដុំលេងយោងមុខ គឺទំនងជាមានន័យថាប្រគុំនាំមុខ។